# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានៈ និងប្តូរឈ្មោះ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបាត់ដំបង ទៅជា វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្របក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១ :** អនុញ្ញាតឱ្យដំឡើងឋានៈ និងប្តូរឈ្មោះ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបាត់ដំបង ទៅជា " វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង " ហៅកាត់ " វ.ប.ប " និងជាភាសាអង់គ្លេស ( Battambang Institute of Technology )

ហៅកាត់ ( B.I.T )។ វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង ស្ថិតនៅក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅ ភូមិរំចេក ៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

**មាត្រា ២** : វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង មានភារកិច្ចធ្វើការបណ្តុះបណ្តាល :

- ថ្នាក់វិញ្ញាបនបត្របណ្តុះបណ្តាល សិក្សារយៈពេលខ្លី ក្រោម ១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សិក្សារយៈពេល ១ឆ្នាំ, ២ឆ្នាំ, ៣ឆ្នាំ
- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ក្រេឌីត
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ក្រេឌីត ។

**មាត្រា ៣** : ចំពោះមុខ វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង មានរចនាសម្ព័ន្ធដូចខាងក្រោម :

១- ការិយាល័យអប់រំបណ្តុះបណ្តាល

២- ការិយាល័យរដ្ឋបាល

៣- ការិយាល័យផែនការ និងហិរញ្ញវត្ថុ

៤- ការិយាល័យសេវាកម្ម និងផលិតកម្ម

៥- ដេប៉ាតឺម៉ង់រថយន្ត និងគ្រឿងយន្តកសិកម្ម

៦- ដេប៉ាតឺម៉ង់អគ្គិសនី និងអេឡិចត្រូនិច

៧- ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា និងគំនូរបោះពុម្ព

៨- ដេប៉ាតឺម៉ង់សំណង់

៩- ដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម

១០- ដេប៉ាតឺម៉ង់ភាសាបរទេស

នៅថ្ងៃអនាគតវិទ្យាស្ថាននេះ អាចបើកដេប៉ាតឺម៉ង់ ឬសាខា ឬឯកទេសដទៃទៀត ដោយរៀបចំសំណើរ ស្នើសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៤** : លក្ខខណ្ឌទទួលសិស្សឱ្យចូលរៀន :

- ថ្នាក់វិញ្ញាបនបត្រ : បេក្ខជនទាំងពីរភេទជាសិក្ខាកាមសិស្ស និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ : បេក្ខជនទាំងពីរភេទបានរៀនចប់ថ្នាក់ទី ៩ នៃមធ្យមសិក្សាបឋមភូមិ
- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង : បេក្ខជនទាំង ២ភេទ មានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត ៣ ឬបានប្រឡងជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រ

ដែលមានតម្លៃស្មើ។

- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ : បេក្ខជនទាំង ២ភេទ មានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស និស្សិតឱ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**មាត្រា ៥** : នាយកនៃវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង មានបុព្វសិទ្ធិស្មើនឹងប្រធាននាយកដ្ឋាន និងមាននាយករង មួយចំនួនជាជំនួយការតាមការចាំបាច់។

វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបានទៀងទាត់តាមការកំណត់។

**មាត្រា ៦** : វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង កាន់កាប់ និងប្រើប្រាស់ប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវឧបត្ថម្ភថវិកាជាតិ សម្រាប់បណ្តុះបណ្តាល និងមានគណនេយ្យដោយឡែក។

**មាត្រា ៧** : និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង និងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**មាត្រា ៩** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងអប់រំ យុវជន និងកីឡា
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- គ្រប់ខេត្ត-ក្រុង
- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ